# អ្នកស្វែងរកសុខលើគំនរទុក្ខអ្នកដទៃ

## ទុក្ខនោះនឹងវិលទៅដល់អ្នកវិញមិនខាន *(បទពាក្យ ៧)*

*លះសុខតិចតួចចោលមិនទុក ព្រោះប្តូរយកសុខធំទូលាយ*
*បណ្ឌិតលះសុខតិចទាំងឡាយ រីករាយសោយផលវិបុលសុខ ។*
*ជនណាប្រាថ្នាសុខដល់ខ្លួន រុកគួនគេឯងឲ្យមានទុក្ខ*
*ច្របូកច្របល់ពៀរច្រើនមុខ មិនរួចពីទុក្ខពៀរវេរា ។*
*លះបង់កាតព្វកិច្ចខ្លួន ទៅស្ទួនធ្វើកិច្ចមិនគាប់ជា*
*ប្រមាទកើតកើនច្រើនមហិមា អាសវៈក៏វាដុះលូតលាស់ ។*
*ជនមានស្មារតីប្រុងក្នុងកាយ ប្រារព្ធឧបាយព្យាយាមខ្ពស់*
*ជានិច្ចៈកាលមិនចន្លោះ លះអស់កិច្ចដែលមិនត្រូវធ្វើ ។*
*កាតព្វកិច្ចបានបំពេញ ឱបាតអស់អញ្ញសព្វសារពើ*
*ស្មារតីដឹងខ្លួនសព្វអន្លើ អាសាវៈមិនទើរមិនសល់ហោង។*
*សម្លាប់មាតាគឺតណ្ហា អស្មិ មានៈ បិតាផង*
*សម្លាប់ទិដ្ឋិទាំងពីរហោង ស្តេចពីរអង្គផងត្រូវប្រហារ ។*
*សម្លាប់ឆ្នាំទ្វារទាំងប្រាំមួយ ទុកដូចជាត្រួយដែនរដ្ឋា*
*នន្ទិរាគៈអ្នកកត់ត្រា ជាព្រាហ្មណ៍អស្ចារ្យដល់និព្វាន។*
*សម្លាប់ម៉ែឪគឺតណ្ហា អស្មិ មានៈ ក្សត្រពីរប្រាណ*
*ទិដ្ឋិទាំងពីរដ៏ចំណាន សម្លាប់ឲ្យបានគ្រឿងរាំង ។*
*សម្លាប់នីវរណៈប្រាំជាខ្លា វិចិកិច្ឆាជាមេខ្លាំង*

បានជាព្រាហ្មណ៍ព្រឹទ្ធរួចទុក្ខ ខីណាសវំ ឱទ្យារិក ។
គ្រប់ពេលសាវ័កព្រះគោត្តម ភ្ញាក់រឭកព្រមថ្ងៃយប់ព្រឹក
ស្មារតីតំកល់ខ្ពស់ពន្លឹក ផ្គងនឹកនូវគុណពោធិញ្ញាណ ។
គ្រប់ពេលសាវ័កព្រះគោត្តម ភ្ញាក់រឭកព្រមយប់ថ្ងៃមាន
ស្មារតីរឭកព្រះធម៌ថ្កាន ជានិច្ចឲ្យបានឆ្លងវដ្តៈ ។
គ្រប់ពេលសាវ័កព្រះគោត្តម ភ្ញាក់រឭកព្រមសព្វភារៈ
យប់ថ្ងៃស្មារតីតំកល់ជាក់ នឹកសង្ឃសាវ័កគ្រប់ទិសទី ។
គ្រប់ពេលសាវ័កព្រះគោត្តម ភ្ញាក់រឭកព្រមមានឥន្ទ្រីយ៍
ថ្ងៃយប់ស្មារតីតែងសម្តី ជានិច្ចអំពី កាយកតា ។
គ្រប់ពេលសាវ័កព្រះគោត្តម ភ្ញាក់រឭកព្រមក្នុងកាយា
ថៃយប់ព្រះទ័យអហឹង្សា រីករាយនឹងការមិនបៀតបៀន ។
គ្រប់ពេលសាវ័កព្រះគោត្តម ភ្ញាក់រឭកព្រមស្មារតីមាន
ថ្ងៃយប់ សតិត្រេកក្នុងឈាន ភាវនាជាយានតាមមាគ៌ា ។
ក្របានសាងខ្លួនជាបព្វជិត ក្រពិតត្រេកអរនឹងបព្វជា
ឃរាសវាសធម៌ក្រគ្រប់គ្រា រួមជនស្មើគ្នាទុក្ខញាំញី ។
រីអទ្ធគូ ដើរផ្លូវឆ្ងាយ ទុក្ខជាប់តាមកាយរាល់នាទី
គួរអីសាងវដ្តៈគាមិនី គួរអីឲ្យទុក្ខតាមជិះជាន់ ។
អ្នកមានសទ្ធាមានសីលខ្ពស់ លាភហើយនឹងយសមានគ្រប់គ្រាន់
ទៅទីណា ៗ គ្រប់តំបន់ ទីនោះមានជនតាមបូជាហោង ៕